**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ប្រ.គ លេខ ១០.០២១/០៩ គជប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី 30 ខែតុលា ឆ្នាំ២០០៩

# សម្ភារៈឯកសារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
# កំពុងបញ្ជូនមកមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប

លេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោត( លធ/ខប ) ទាំង២៤ បាននឹងកំពុងដឹកជញ្ជូនសម្ភារៈឯកសារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមកមជ្ឈមណ្ឌលកុំព្យូទ័រ ដើម្បីឱ្យមជ្ឈមណ្ឌលនេះផលិតជាបញ្ជីបោះឆ្នោត សម្រាប់ដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប ) ផ្តល់សុពលភាពឱ្យក្លាយជាបញ្ជីបោះឆ្នោតផ្លូវការនាចុងខែធ្នូខាងមុខនេះ ។

លោកយឿង កុសល ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រ បានមានប្រសាសន៍ថា លធ/ខប បានប្រមូលឯកសារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់ទាំង១៦២១ ហើយធ្វើការបញ្ជូនមកមជ្ឈមណ្ឌលដើម្បីផលិតជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ឆ្នាំ២០០៩ ។ ការដឹកជញ្ជូនចាប់ផ្តើមពីថ្ងៃទី២៨ ខែតុលា ដល់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយឯកសារទាំងនេះរួមមាន បញ្ជីដំបូង បង្កាន់ដៃចុះឈ្មោះបោះឆ្នោតថ្មី ទម្រង់បែបបទលុបឈ្មោះ ។ល ។

លោកបានបញ្ជាក់ថា ឥឡូវនេះមន្ត្រី បុគ្គលិកនៅមជ្ឈមណ្ឌលកំពុងធ្វើការពិនិត្យផ្ទៀងផ្ទាត់ឯកសារយ៉ាងយកចិត្តទុកដាក់តាមនីតិវិធី ។ ហើយនៅថ្ងៃទី១ ខែវិច្ឆិកា បុគ្គលិកបញ្ចូលទិន្នន័យដែលបានជ្រើសរើសកាលពីខែសីហាកន្លងមកនេះ នឹងចូលបំរើការងារដើម្បីអនុវត្តការងាររៀបចំផលិតបញ្ជីបោះឆ្នោត ។

តាមប្រតិទិនការងារ ការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតឆ្នាំ២០០៩ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ។

ខាងក្រោមនេះជាតារាងពេលវេលាដែល លធ/ខប ដឹកឯកសារ សម្ភារៈមកមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប ÷

| ល.រ | ឈ្មោះរាជធានី ខេត្ត | ពេលវេលាត្រូវដឹកឯកសារមកដល់មជ្ឈមណ្ឌល |
|---|---|---|
| ១ | កំពង់ឆ្នាំង កំពត កែប រតនៈគិរី និងពោធិ៍សាត់ | ២៨-១០-២០០៩ |
| ២ | ព្រះសីហនុ ស្វាយរៀង ស្ទឹងត្រែង និងប៉ៃលិន | ២៩-១០-២០០៩ |
| ៣ | កំពង់ចាម និងភ្នំពេញ | ៣០-១០-២០០៩ |
| ៤ | កំពង់ធំ និងតាកែវ | ៣១-១០-២០០៩ |
| ៥ | កណ្តាល និងកោះកុង | ០១-១០-២០០៩ |
| ៦ | ព្រៃវែង | ០២-១១-២០០៩ |
| ៧ | ព្រះវិហារ | ០៣-១១-២០០៩ |
| ៨ | ក្រចេះ និងបាត់ដំបង | ០៤-១១-២០០៩ |
| ៩ | ឧត្តរមានជ័យ និងសៀមរាប | ០៥-១១-២០០៩ |
| ១០ | បន្ទាយមានជ័យ មណ្ឌលគិរី និងកំពង់ស្ពឺ | ០៦-១១-២០០៩ |

ព័ត៌មានបន្ថែម សូមទំនាក់ទំនងផ្នែកព័ត៌មាន ទូរស័ព្ទលេខ៖ 023 214 231 / 012 855 018 & Fax 023 214 374